# សាររបស់លោកអភិបាល អូលីវីយេ
# ផ្ញើទៅយុវជនយុវនារីភូមិភាគភ្នំពេញ
# ចំការទៀង ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០

យុវជនយុវនារីជាទីស្រឡាញ់!

នេះជាពែងកាលី ដែលជាកាដូរបស់អ៊ុំជូនមកខ្ញុំ នៅថ្ងៃខ្ញុំទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ។ ជួនកាល យើងគិតថាពេលយើងក្លាយទៅជាបូជាចារ្យ បីដូចជាយើងចោលគ្រួសារយើង យើងទៅឆ្ងាយពីឪពុកម្ដាយ ជាពិសេសសម្រាប់យើងជាសាសនទូតយើងត្រូវនៅឆ្ងាយពិតមែន។ ទោះបីជា យើងនៅឆ្ងាយ យើងមិននៅផ្ទះជាមួយឪពុកម្ដាយ ប៉ុន្តែយើងភ្ជាប់ជាមួយឪពុកម្ដាយយើងជានិច្ច។ នៅក្នុងពែងកាលីនេះខ្ញុំបានឆ្លាក់អក្សរខ្លះៗ ដែលជាអក្សរកាត់ឈ្មោះបងប្អូនខ្ញុំទាំងបួននាក់ ឈ្មោះឪពុកម្ដាយខ្ញុំ និងឈ្មោះយាយតាខ្ញុំ។ ដូច្នេះ គ្រប់ពេលវេលាដែលខ្ញុំថ្វាយអភិបូជា ដូចជាខ្ញុំបានភ្ជាប់ជាមួយគ្រួសារខ្ញុំផ្ទាល់ ដោយដឹងថាគ្រួសារខ្ញុំ ពួកគាត់ក៏បានអធិដ្ឋានសម្រាប់ខ្ញុំ។

ដូច្នេះ ខ្ញុំចង់និយាយថាសូមកុំព្រួយបារម្ភ កុំគិតថាយើងចោលឪពុកម្ដាយ មិនមែនទេ តាមពិតយើងមានឪពុកម្ដាយនៅក្នុងចិត្តរបស់យើងតែនៅក្នុងរបៀបថ្មី។ ខ្ញុំក៏បានសរសេរ កាលបរិច្ឆេទនៃពិធីតែងតាំងខ្ញុំជាបូជាចារ្យ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៩៨ និងខ្ញុំថែមឃ្លាមួយថា "**ខ្ញុំបានទទួលតែងតាំងដោយសេចក្ដីស្រឡាញ់**"។ នេះជាមូលហេតុ យើងអាចឆ្លើយទៅព្រះយេស៊ូបាន ដើម្បីបម្រើព្រះយេស៊ូអស់មួយជីវិត ដោយសារសេចក្ដីស្រឡាញ់។ ប្រសិនបើ អត់មានសេចក្ដីស្រឡាញ់ទេនោះ យើងទៅមុខមិនបានឡើយ ហើយខ្ញុំជឿថាយុវជនយុវនារី ដែលមានស្នេហាជាមួយបុរសស្ត្រីក៏ដូចគ្នាដែរ។ ពេលយើងមានស្នេហាពិត ពេលយើងមានសេចក្ដីស្រឡាញ់ពិត យើងពិតជាអាចទៅមុខបាន ជាមួយព្រះយេស៊ូក៏ដូចគ្នាដែរ នៅពេលយើងឆ្លើយតបដោយសេចក្ដីស្រឡាញ់ យើងក៏អាចទៅមុខអស់មួយជីវិតបានដែរ។